| Student/Registration Number | | | | | | | | | | | | Centre Number | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | | | | |

**2023** PUBLIC EXAMINATION

# Khmer

## Continuers Level

**Wednesday 18 October: 2 pm Australian Eastern Daylight Time**

Reading Time: 10 minutes
Writing Time: 2 hours and 30 minutes

- *You have 10 minutes to read all the papers and to familiarise yourself with the requirements of the questions. You MUST NOT write during this time.*
- *Monolingual and/or bilingual printed dictionaries may be consulted during the reading time and also during the examination.*

## Section 1: Listening and Responding (30 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 1.
2. Write all your answers to the questions in Section 1 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2023*

## **Part A** (Questions 1 to 3)
(15 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

---

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in ENGLISH.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 1**

1. Complete the following table. **3**

   What do the following numbers from the text relate to?

| Number | Relates to |
|---|---|
| 1.15 m | |
| 479 km | |
| 10 m | |

*Vocabulary*

បុរាណវិទូ — archaeologist

Marks

You may make notes in this space. These notes will NOT be assessed.

**Text 2**

2. (a) What type of text is this? **1**

_______________________________________________

_______________________________________________

(b) What emotions are conveyed in this text? Provide *two* examples and support these with evidence from the text. **4**

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

Marks

You may make notes in this space. These notes will NOT be assessed.

**Text 3**

3. (a) How do the two speakers know each other? **1**

(b) Compare and contrast the speakers' views as expressed in the text. **6**

**Part B** (Questions 4 to 6)
(15 marks)

*Your response will be assessed on how well you:*

- *understand general and specific aspects of texts by identifying and analysing information and convey the information accurately and appropriately.*

You will hear THREE texts. Each text will be played twice. There will be a short break between the first and second playings of each text. You may make notes at any time.

Listen carefully to each text and then answer the questions in KHMER.

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 4**

4. (a) Where would this announcement be heard? **1**

តើអ្នកអាចឮសេចក្តីប្រកាសនេះនៅកន្លែងណា?

(b) Why is the speaker apologising? **1**

តើហេតុអ្វីបានជាអ្នកប្រកាសសុំទោស?

(c) Based on the information heard, what items would be most useful to have with you? Support your answer with evidence from the text. **2**

ផ្អែកតាមសេចក្តីប្រកាសដែលអ្នកបានឮ តើសំភារៈណាខ្លះដែលមានប្រយោជន៍បំផុតសម្រាប់អ្នកយកទៅជាមួយ ?គាំទ្រចម្លើយអ្នកដោយស្រង់ភស្តុតាងពីអត្ថបទ

**Marks**

You may make notes in this space. These notes will NOT be assessed.

**Text 5**

5. How useful do you think Dave's advice is? Support your answer with examples from the text. **6**

   តើដំបូន្មានរបស់ដេវមានប្រយោជន៍អ្វីខ្លះ? គាំទ្រចម្លើយរបស់អ្នក ដោយស្រង់ភស្តុតាងពីអត្ថបទ។

*Vocabulary*

កៅឆាយ — sale to the first customer

| | Marks | |
|---|---|---|
| | | You may make notes in this space. These notes will NOT be assessed. |

**Text 6**

6. (a) Who is the speaker likely to be? Support your answer with evidence from the text. **2**

តើអ្នកនិយាយអាចជានរណា? គាំទ្រចម្លើយរបស់អ្នកដោយស្រង់ភស្តុតាងពីអត្ថបទ។

(b) Why is this event described as significant? **2**

ហេតុអ្វីបានជាគេពិពណ៌នាថាការប្រារព្ធពិធីនេះមានសារៈសំខាន់?

(c) Provide an example from the text of how the speaker uses language to show their enthusiasm for the event. **1**

ចូររកឧទាហរណ៍មួយ ពីក្នុងអត្ថបទដែលអ្នកនិយាយបង្ហាញភាពរំភើបរីករាយទៅកាន់អ្នកចូលរួម។

**End of Section 1**

**KHMER (CONTINUERS) EXAMINATION 2023**

**Section 1: Listening and Responding**

**PART A**

***Text 1***

នេះជាកម្មវិធីវិទ្យុខ្មែរ RBKផ្សាយនៅប្រទេសកម្ពុជាពីទីក្រុងភ្នំពេញ រៀងរាល់ថ្ងៃច័ន្ទចាប់ពីម៉ោង ៨.០០ដល់ម៉ោង៨.៣០នាទីព្រឹក។
ឥឡូវនេះយើងមានព័ត៌មានអន្តរជាតិ។ (បញ្ចូលភ្លេងខ្លី)

កាលពីថ្ងៃសុក្រ ទី១២ ខែមីនា ឆ្នាំ២០២២ បុរាណវិទូអូស្ត្រាលីបានរកឃើញឆ្អឹងមនុស្ស ១ម៉ែត្រ១៥ ដែលបានកប់ជម្រៅ១០ម៉ែត្រ
ក្រោមដីនៅតំបន់ដាច់ស្រយាលនៃទីក្រុងឃ្វីនស្លែន ចម្ងាយ៩៧៩គ.ម ពីទីក្រុងប្រីសបិន។
បន្ទាប់ពីការធ្វើកោសល្យវិច័យដោយប្រុងប្រយ័ត្នលើឆ្អឹង បុរាណវិទូបានប៉ាន់ប្រមាណថា គ្រោងឆ្អឹងមនុស្សនេះមានអាយុកាល
តាំងពី២ពាន់ឆ្នាំមុនម្ល៉េះ។ អ្នកវិទ្យាសាស្ត្រមកពីជុំវិញពិភពលោករួមទាំងប្រទេសកម្ពុជា មានចំណាប់អារម្មណ៍ជាខ្លាំងចំពោះគំហើញថ្មីនេះ។

*Text 2*

សូមស្វាគមន៍ការត្រឡប់មកវិញ។ សម្រាប់អ្នកដែលទើបតែបានចូលរួមជាមួយយើង
ការប្រកួតនៅសល់តែ៣នាទីប៉ុណ្ណោះ ហើយពិន្ទុ        គឺ៣ទល់៣។
ខ្ញុំមិនអាចចាំមើលលទ្ធផលបានទេ! វាមានភាពតឹងតែងពេក!
ប្រទេសកម្ពុជាមិនបានចូលវគ្គផ្តាច់ព្រ័ត្រអស់រយៈពេល៦ឆ្នាំហើយតើគេអាចធ្វើបានទេនៅឆ្នាំនេះ?
មើល៍នេះ! សេមចាប់បាល់បានសម្រាប់ក្រុមខ្លួន ហើយទាត់ទៅឲ្យដារ៉ា ម៉េចបានចឹង???វាអត់ត្រូវ!!!
មានរឿងអី! ខ្ញុំអត់យល់ទេ! អាជ្ញាកណ្តាលត្រូវការវ៉ែនតា?? ចាំមួយភ្លែតអូ ………..!

មើល! មើល! នេះជាបាល់!ផានទទួលបានវាហើយ!ផាន កំពុងរាំជាមួយបាល់.... វាល្អមើលណាស់!
គ្មានអ្នកណាអាចដណ្តើមគាត់បានទេ។គាត់រត់លឿនដូចព្យុះ!
ឥឡូវផានកំពុងត្រៀមទាត់បាល់ចូលទី តើគាត់នៅឆ្ងាយពេកទេហ្អី? ជយោ ជយោ!គោលដៅ
ពិន្ទុ៤ទល់នឹង៣!!!! ... អស្ចារ្យដែលផានទាត់ចូលទីហើយទទួលបានពិន្ទុ!!!! ... ល្អមែនទែន !
តើកម្ពុជាត្រូវការអ្វីទៀតបើពិន្ទុ៤ ទល់នឹង៣ហើយហ្នឹង។
អស្ចារ្យណាស់ដែលគាត់ទាត់ចូលបានពិន្ទុ។ ហ្នឹងហើយដែលខ្ញុំកំពុងនិយាយពីផាន
អ្នកជាគ្រាប់ពេជ្ររបស់កម្ពុជា! អ្នកដឹងថាត្រូវតែទាត់បញ្ចូលទី។
នេះគឺជាប្រវត្តិសាស្ត្រដែលត្រូវបានបង្កើតឡើង។ អ្នកធ្វើឲ្យប្រទេសកម្ពុជាយើង ក្រុមយើង
ព្រមទាំងខ្ញុំ មានមោទនភាព!!        ៤ទល់នឹង៣សម្រាប់ពួកយើង។ យើង!បានឈ្នះ!
កម្ពុជាទទួលបានជ័យជំនះ! ក្រុមកម្ពុជានឹងបន្តទៅវគ្គ ផ្តាច់ព្រ័ត្រហើយ!

***Text 3***

**សុចាន់** : សួស្តីឪណាសុខសប្បាយជាទេ? ខ្ញុំបានឮថា
ឆ្នាំនេះសាលារៀននឹងមិនអនុញ្ញាតឲ្យសិស្សប្រើប្រាស់ទូរស័ព្ទនៅក្នុងថ្នាក់ទេ។
ខ្ញុំរីករាយដែលសាលាសាកល្បងរឿងនេះរយៈពេលមួយឆ្នាំ ។

**ឪណា**: បាទខ្ញុំបានឮដំណឹងនេះពីកូនប្រុសខ្ញុំ។ ខ្ញុំមិនសូវយល់ស្របទេពីព្រោះ
ថាតើខ្ញុំនឹងទាក់ទងកូនរបស់ខ្ញុំយ៉ាងម៉េចនៅពេលមានបញ្ហាបន្ទាន់?

**សុចាន់**: ចាសខ្ញុំយល់ពីកង្វល់របស់ឪណា
ប៉ុន្តែឪណាអាចទាក់ទងទៅសាលាបានគ្រប់ពេលបើមានបញ្ហាបន្ទាន់។ ខ្ញុំគិតថា
ខ្ញុំយល់ស្របនឹងច្បាប់របស់សាលារៀន ពីព្រោះនៅពេលសិស្សប្រើទូរស័ព្ទក្នុងថ្នាក់
ពួកគេមិនសូវផ្តោតអារម្មណ៍លើមេរៀននោះទេ។
ពួកគេអាចនឹងប្រើទូរស័ព្ទសម្រាប់ជជែកជាមួយមិត្តភក្តិឬលេងហ្គេមជាដើម។
កូនស្រីខ្ញុំចំណាយពេលច្រើនណាស់ទៅលើទូរស័ព្ទ។
ការហាមមិនឲ្យប្រើទូរស័ព្ទនៅសាលាគឺជាគំនិតល្អមួយ។

**ឪណា**: ខ្ញុំនៅតែមិនយល់ស្របទេសុចាន់
យើងអាចណែនាំពួកគេមិនឱ្យប្រើទូរស័ព្ទច្រើនពេកដោយមិនចាំបាច់មានបម្រាមទេ។ខ្ញុំគិតថា
សិស្សទទួលបានផលប្រយោជន៍ច្រើនពីការប្រើទូរស័ព្ទនៅក្នុងថ្នាក់ដូចជា
ការធ្វើការស្រាវជ្រាវមេរៀន និងកត់ត្រាតាមរយៈការថតរូបមេរៀនផ្សេងៗ។

**សុចាន់៖** ឪណាដឹងទេថា ពេលណាក្មេងៗញៀននឹងការប្រើទូរស័ព្ទ
ពួកគេមិនអាចគ្រប់គ្រងថាពេលណាត្រូវប្រើនិង ពេលណាមិនត្រូវប្រើទូរស័ព្ទ នោះទេ។
ជាពិសេសទៅទៀត ផលប៉ះពាល់អវិជ្ជមានមួយចំនួនរបស់ទូរស័ព្ទដែលមិនអាចមើលរំលងគឺ
ការប្រមាទគ្នាតាមអ៊ីនធើណែត ខ្ញុំគិតថាបម្រាមនៃការប្រើទូរស័ព្ទនៅក្នុងថ្នាក់
គឺជាដំណោះស្រាយដ៏ល្អមួយ។

ឪណា៖ បាទវាដូចជាសមហេតុផលដែរ ប៉ុន្តែខ្ញុំរីករាយដែលបម្រាមនេះគ្រាន់តែជា
ការសាកល្បងរយៈពេល១ឆ្នាំ។ខ្ញុំនឹងរង់ចាំមើលលទ្ធផលនៃច្បាប់នេះ។

**PART B**

***Text 4***

សូមអរគុណអស់លោកលោកស្រីដែលបានធ្វើដំណើរជាមួយយើងខ្ញុំនៅថ្ងៃនេះ ។
ដោយសារអាកាសធាតុមិនល្អយន្តហោះត្រូវបានពន្យារពេល30នាទី
ហើយឥឡូវនេះយើងនឹងទៅដល់ទីក្រុងឃ្វីនស្លែននៅម៉ោង 2.30នាទីរសៀល។
ខ្ញុំសូមអភ័យទោសចំពោះការយឺតយ៉ាវនេះ។
សូមអស់លោកលោកស្រីត្រឡប់ទៅកាន់កន្លែងអង្គុយរបស់លោកអ្នកវិញ
ហើយសូមកុំភ្លេចឥវ៉ាន់និងសំភារៈចាំបាច់ផ្ទាល់ខ្លួនរបស់
លោកអ្នក។ យើងខ្ញុំសង្ឃឹមថា លោកអ្នករីករាយការធ្វើដំណើរជាមួយយើងខ្ញុំ។
ពេលនេះនៅក្នុងទីក្រុងឃ្វីនស្លែនគឺម៉ោង1.30នាទីរសៀលហើយមានសីតុណ្ហភាព17អង្សា
ហើយនឹងមានភ្លៀងនៅល្ងាចនេះ។

***Text 5***

កិច្ចសន្ទនា៖ ដំបូន្មានសម្រាប់ការទិញទំនិញក្នុងទីផ្សារនៅកម្ពុជា (អ្វី ដែល ត្រូវធ្វើ និងមិនត្រូវធ្វើ)

**ផានី៖**អេ!ដេវ ខ្ញុំលឺព្យថាឯងបានទៅលេងប្រទេសកម្ពុជានាពេលថ្មីៗនេះ តើពិតមែនទេ?

**ដេវ៖** បាទខ្ញុំបានទៅមែនហើយសប្បាយណាស់។ ខ្ញុំបានជួបក្រុមគ្រួសារនៅទីនោះ

ទៅមើលទេសភាពនានា ទៅញុំាអាហារឆ្ងាញ់ៗ ជាច្រើនមុខ

ហើយទៅទិញឥវ៉ាន់នៅផ្សារផងដែរ ។

**ផានី៖** ស្តាប់ទៅសប្បាយណាស់។ ខ្ញុំគ្រោងទៅលេងស្រុកខ្មែរនៅឆ្នាំក្រោយ។

ខ្ញុំចូលចិត្តទិញឥវ៉ាន់ណាស់ ខ្ញុំទន្ទឹងរង់ចាំពេលទៅដើរផ្សារទិញវត្ថុអនុស្សាវរីយ៍។

**ដេវ៖** ផានីនឹងចូលចិត្តផ្សារនៅទីនោះ

ប៉ុន្តែការទិញទំនិញនៅស្រុកខ្មែរពិតជាខុសប្លែកពីការទិញទំនិញនៅទីនេះខ្លាំងណាស់។

ផានី៖ ពិតមែនហ្អី! ខុសម៉េចទៅ?

ដេវ:  ជាទូទៅពេលទិញឥវ៉ាន់នៅស្រុកខ្មែរ ផានីត្រូវតថ្លៃដើម្បីទទួលបានតម្លៃសមរម្យ។

**ផានី៖** ខ្ញុំព្រួយបារម្ភថាអ្នកលក់មិនសប្បាយចិត្តទេ។

**ដេវ** ៖កុំបារម្ភផានី។ អ្នកលក់មិនសូវប្រកាន់ទេ នៅពេលដែលផានីឲ្យតម្លៃសមរម្យនិង

និយាយទន់ភ្លន់ទៅកាន់ពួកគេ។

អ្នកលក់សប្បាយចិត្តព្រោះឯងចាប់អារម្មណ៍នឹងទំនិញរបស់ពួកគាត់។ ជាពិសេសនៅព្រឹកព្រលឹម

ពួកគេពិតជាចង់លក់ឥវ៉ាន់ដាច់ណាស់ ព្រោះពួកគេជឿថានៅពេលកៅឆាយ

ពួកគេអាចនឹងលក់ដាច់ឥវ៉ាន់បានច្រើនពេញមួយថ្ងៃ។

**ផានី៖** អូ!ពិតជាគួរឲ្យចាប់អារម្មណ៍ណាស់។ និយាយអញ្ចឹង! តើដេវអាចផ្តល់យោបល់បានទេថា

តើខ្ញុំគួរទិញវត្ថុអនុស្សាវរីយ៍អ្វីដែលប្លែក ហើយគួរអោយចាប់អារម្មណ៍ទៅ?

**ដេវ៖**ខ្ញុំអត់បានទិញវត្ថុអនុស្សាវរីយ៍ជាយូរមកហើយ។ខ្ញុំពិតជាអត់ដឹងថាផ្តល់គំនិតអោយផានីទិញអ្វី

ល្អទេ។

ផានី: អត់អីទេដេវ។ ខ្ញុំជឿជាក់ថា ខ្ញុំនឹងរកទិញទំនិញល្អៗបាន។

អរគុណច្រើនដេវ ដែលបានប្រាប់ខ្ញុំពីរបៀបទិញឥវ៉ាន់នៅស្រុកខ្មែរ។

ដេវ៖មិនអីទេផានី។ខ្ញុំសង្ឃឹមថា ផានីនឹងរីករាយជាមួយការធ្វើដំណើរទៅទីនោះ។

**កៅឆាយ  លក់បើកមុខទៅអតិថិជនដំបូង**

***Text 6***

អាឡូ អាឡូ! សូមស្ងាត់បន្តិចបានទេ! ខ្ញុំពិតជារំភើបខ្លាំងណាស់
ក្នុងការស្វាគមន៍អ្នកទាំងអស់គ្នាមកចូលរួមពិធីបុណ្យវិសាខបូជា។ ឆ្នាំនេះជាឆ្នាំថោះ
ពុទ្ធសករាជ២៥៦៦។ នេះជាឆ្នាំទី១ដែលពួកយើងមានសំណាងយ៉ាងខ្លាំង
ពីព្រោះមានពុទ្ធបរិស័ទមកពីវត្តចំនួន៣មកចូលរួមក្នុងពិធីបុណ្យជុំគ្នានៅ
កន្លែងតែមួយនិងក្នុងពេលតែមួយ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអស់លោក
លោកស្រីដែលបានមកចូលរួមប្រារព្ធពិធីបុណ្យជុំគ្នា។
អរគុណសាជាថ្មីម្តងទៀត។ ខ្ញុំសង្ឃឹមថាអស់លោក
លោកស្រីទាំងអស់គ្នារីករាយជាមួយការប្រារព្ធពិធីដ៏សំខាន់នេះ ។

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

# 2023 PUBLIC EXAMINATION

# Khmer

## Continuers Level

## Section 2: Reading and Responding (25 marks)

**Instructions to Students**

1. Allow approximately 1 hour and 10 minutes for Section 2.
2. Write all your answers to the questions in Section 2 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ALL questions in Part A and Part B.
4. Answer Part A in ENGLISH and Part B in KHMER.
5. Write your student/registration number and the centre number (if required) on the front cover of this booklet.
6. All question booklets will be collected at the end of the examination.

*© SACE Board of South Australia 2023*

**Part A** (Question 7)
(10 marks)

---

*Your response will be assessed on how well you:*

- *understand general and specific aspects of texts (for example, by comparing, contrasting, summarising, and/or evaluating) and convey the information appropriately.*

---

7. Read the text and then answer in ENGLISH the questions that follow.

### TopDinerAdvisor.com, ការវាយតម្លៃដ៏ល្អបំផុតនៅប្រទេសអូស្ត្រាលី
### ភោជនីយដ្ឋានឈូករ័ត្ន

**1. គុណភាព និង រសជាតិ**

ខ្ញុំកើតនិងធំឡើងនៅស្រុកខ្មែរ ហើយខ្ញុំចូលចិត្តម្ហូបខ្មែរខ្លាំងណាស់។ ខ្ញុំយល់ថាភោជនីយដ្ឋានឈូករ័ត្នផ្តល់សេវាកម្មល្អដល់អតិថិជន ប៉ុន្តែខ្ញុំមានអារម្មណ៍ថាអាហារមិនមានរសជាតិដើមទេ។ រសជាតិមានការផ្លាស់ប្តូរដើម្បី បំពេញតម្រូវការអតិថិជននៅទីនេះដែលធ្វើអោយរសជាតិអាហារមិនមានរសជាតិដូចកាលពីមុនដូចការគិតរបស់ខ្ញុំទេ។

ថ្ងៃទី១៥ ខែមករា ២០២១

**2. តម្លៃ សេវា និងគុណភាព**

ខ្ញុំបានទៅបរិភោគអាហារពេលល្ងាចនៅទីនោះជាមួយមិត្តភក្តិកាលពីបីខែមុន។ អាហារដែលខ្ញុំកុម្ម៉ង់មានរសជាតិឆ្ងាញ់គួរសម ទោះបីជាវាមិនដូចការរំពឹងទុករបស់ខ្ញុំក៏ដោយ។ ខ្ញុំពិតជាចង់អោយអាហារមានរសជាតិដូចជាអាហារដែលខ្ញុំបានញ៉ាំពេលខ្ញុំទៅលេងនៅស្រុកខ្មែរណាស់។ តម្លៃអាហារថោកគួរសមតែសេវាកម្មយឺតណាស់។ ខ្ញុំត្រូវរង់ចាំ៣០នាទីដែលជាពេលវេលាយូរមែនទែន។ ខ្ញុំឃ្លានខ្លាំងណាស់ហើយមិនសូវសប្បាយចិត្តទេ។ យើងទទួលបានអាហារដែលមានបរិមាណច្រើន ប៉ុន្តែខ្ញុំគិតថាមានភោជនីយដ្ឋានខ្មែរជាច្រើនទៀតដែលអ្នកអាចទៅញ៉ាំបាន។

ថ្ងៃទី១ខែ មីនា ២០២១

**3.**

ខ្ញុំជាកូនខ្មែរដែលកើតនៅទីនេះហើយខ្ញុំចូលចិត្តអាហារខ្មែរណាស់។ ខ្ញុំមិនដែលខកចិត្តនឹងអាហារនិងការផ្តល់សេវានៅទីនេះទេ។អាហារមានរសជាតិដើមពិតប្រាកដព្រោះចុងភៅប្រើគ្រឿងផ្សំត្រឹមត្រូវទៅតាមប្រភេទអាហារនីមួយៗ។ អាហារដែលមនុស្សចូលចិត្តញ៉ាំបំផុតពេលល្ងាចរួមមាន អាម៉ុក, នំបញ្ចុក, ការី និងញាំ។ អាហារស័ក្តិសមជាមួយតម្លៃទោះបីជាវាថ្លៃបន្តិច។ បុគ្គលិកមានភាពរួសរាយណាស់ដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ល្អគ្រប់ពេល។ ពួកគេជាជនជាតិខ្មែរ

ដូច្នេះពួកគេអាចជួយប្រាប់អំពីមុខម្ហូបខ្លះៗបើសិនជាអ្នកមិនដឹងថាចង់កុម្ម៉ង់អ្វីញ៉ាំ។ ខ្ញុំសូមធ្វើការណែនាំដល់អ្នកណាដែលចង់សាកល្បងម្ហូបខ្មែរដែលពិសេសនៅទីនេះ។ តើអ្នកនៅរង់ចាំអ្វីទៀត?ធ្វើការកុម្ម៉ង់នៅថ្ងៃនេះ!

២៧ មេសា ២០២៣

**4.**

ខ្ញុំបានទៅបរិភោគអាហារពេលល្ងាចនៅទីនោះម្តង។ បរិយាកាសក្នុងហាងល្អព្រមជាមួយនឹងការតុបតែងយ៉ាងស្អាត។ បុគ្គលិកមានការប្រយ័ត្នប្រយែងជាមួយការកុម្ម៉ង់របស់ភ្ញៀវដោយបានសួរអតិថិជនបញ្ជាក់ម្តងទៀតមុនពេលចំអិនម្ហូប។ រសជាតិរបស់ញ៉ាំសាច់មាន់គឺស្រស់ៗ និងមានរសជាតិឆ្ងាញ់ ដោយសារតែការប្រើបន្លែ សាច់និង គ្រឿងផ្សំផ្សេងទៀតមានភាពត្រឹមត្រូវ។ ប៉ុន្តែរឿងមួយដែលខ្ញុំមិនសប្បាយចិត្តខ្លាំងនោះគឺថា ពួកគេមិនបានផ្តល់សេវាដល់អតិថិជនតាមលំដាប់លំដោយត្រឹមត្រូវនោះទេ។ ខ្ញុំបានកុម្ម៉ង់អាហារមុន ប៉ុន្តែខ្ញុំទទួលបានអាហារក្រោយអតិថិជនដែលចូលមកកុម្ម៉ង់អាហារបន្ទាប់ពីពួកយើង។

ថ្ងៃទី២៩ ខែមិថុនា ២០២៣

*Vocabulary*
នំបញ្ចុក — Cambodian noodle soup
ញ៉ាំ — salad

QUESTION

**Marks**

(a) Based on the text, suggest a suitable title for **both** Review 3 and Review 4. **2**

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

(b) Based on the text, would you recommend someone who dined at this restaurant in 2021 to try it again in 2023? Justify your recommendation with evidence from the text. **5**

(c) Which of the reviewers have a connection to Cambodia? Support your answer with evidence from the text. **3**

This page is intentionally blank

**Part B** (Question 8)
(15 marks)

---

*Your response will be assessed on how well you:*

- *demonstrate understanding of the stimulus text*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

8. Read the text and then answer the question in approximately 150 words in KHMER.

## សមាគមខ្មែរនៅអូស្រ្តាលី(CAA)
## ត្រូវការអ្នកស្ម័គ្រចិត្ត

**សមាគមខ្មែរនៅអូស្រ្តាលី(CAA)** គឺជាអង្គភាពមួយដែលត្រូវបានបង្កើតឡើងដើម្បីថែរក្សាប្រពៃណីវប្បធម៌ខ្មែរតាមរយ: ការរៀបចំកម្មវិធីប្រពៃណីសំខាន់ៗប្រចាំឆ្នាំ។ គោលបំណងរបស់CAA គឺដើម្បីភ្ជាប់ទំនាក់ទំនងប្រជាជនកម្ពុជាគ្រប់ស្រទាប់នៅក្នុងសហាគមន៍អោយចូលរួមសប្បាយរួមគ្នានៅក្នុងកម្មវិធីសំខាន់ៗ។ ឆ្នាំនេះCAAនឹងរៀបចំកម្មវិធីពិសេសមួយក្នុងអំឡុងបុណ្យចូលឆ្នាំខ្មែរដូចជា ការធ្វើម្ហូបអាហារដើម្បីប្រគេនដល់ព្រះសង្ឃ និង សមាជិក។ អ្វីដែលពិសេសជាងនេះទៅទៀតCAA នឹងរៀបចំការរាំបែបប្រពៃណីនៅពេលល្ងាចដូច្នេះជនជាតិខ្មែរទាំងអស់អាចមកចូលរួមសប្បាយរួមគ្នា។ សមាគមស្វែងរកអ្នកស្ម័គ្រចិត្តបីនាក់ដើម្បីមកជួយក្នុងកម្មវិធីនេះ។

លក្ខណ:សម្បត្តិសំខាន់ៗមានដូចជា៖

1. អាចនិយាយភាសាខ្មែរ និងភាសាអង់គ្លេសបានដើម្បីជួយបកប្រែអោយអ្នកចូលរួម
2. ចេះធ្វើម្ហូបខ្មែរ
3. មានជំនាញរៀបចំចាត់ចែងកម្មវិធីផ្សេងៗ
4. មានទំនុកចិត្តក្នុងការនិយាយជាសាធារណ:ដើម្បីអាចពន្យល់ អំពីពិធីបុណ្យចូលឆ្នាំខ្មែរ និងសារ:សំខាន់របស់វា។
5. ចេះរាំរបាំប្រពៃណីខ្មែរ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**លោកតាន់ ដារ៉ា** ដែលជាបុគ្គលិកសមាគម CAAតាមរយ: អ៊ីម៉ែល dara.tan@cassociation.org.au .

*Vocabulary*
សមាគមខ្មែរនៅអូស្រ្តាលី(CAA) — Cambodian Association in Australia

QUESTION

You previously volunteered at this event. Write an email to your friend Dany to persuade them to volunteer with you this year, even though they do not meet all of the listed criteria.

អ្នកធ្លាប់បានចូលរួមក្នុងកម្មវិធីសហគមន៍នេះពីមុន។ សរសេរអ៊ីម៉ែលដើម្បីបញ្ចុះបញ្ចូលមិត្តភក្តិរបស់អ្នកឈ្មោះដានីឲ្យមកចូលរួមស្ម័គ្រចិត្ត ក្នុងពេលចូលឆ្នាំខ្មែរជាមួយអ្នកនៅឆ្នាំនេះ ទោះបីជាដានីមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក៏ដោយ។

---

You may make notes in this space.

This page is intentionally blank

Question 8



PLEASE TURN OVER

**End of Section 2**

Student/Registration Number | | | | | | | | | | | Centre Number | | | | | | |

**2023** PUBLIC EXAMINATION

# Khmer

## Continuers Level

### Section 3: Writing in Khmer (20 marks)

**Instructions to Students**

1. Allow approximately 40 minutes for Section 3.
2. Write your answer to a question from Section 3 in this booklet using black or blue pen. Space is provided for you to make notes.
3. You must answer ONE question in KHMER.
4. Write your student/registration number and the centre number (if required) on the front cover of this booklet.
5. All question booklets will be collected at the end of the examination.

© SACE Board of South Australia 2023

**Section 3** (Questions 9 to 11)
(20 marks)

---

*Your response will be assessed on how well you:*

- *demonstrate depth of treatment of information, ideas and/or opinions*
- *write text that is appropriate and relevant to context, purpose, and audience*
- *structure and sequence information and ideas*
- *manipulate language structures and vocabulary in Khmer.*

---

Answer ONE question from this section in approximately 250 words in KHMER.

9. Write a diary entry in which you reflect on the best gift you have ever received and the significant impact it had on you.

   ចូរសរសេរនៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃមួយ ដោយឆ្លុះបញ្ចាំងពីឥទ្ធិពលយ៉ាងសំខាន់របស់អំណោយដ៏ពិសេសបំផុតចំពោះអ្នកដែលធ្លាប់បានទទួលវា។

10. You have decided on a future career, but your parents disagree with your choice. Write an email to a friend explaining the situation and asking for their advice.

    អ្នកបានធ្វើការសម្រេចចិត្តអំពីមុខរបរពេលអនាគតរបស់អ្នក ប៉ុន្តែឪពុកម្ដាយរបស់អ្នកជំទាស់នឹងការសម្រេចចិត្តរបស់អ្នក។ ចូរសរសេរអ៊ីមែលមួយទៅកាន់មិត្តភក្តិរបស់អ្នកដោយពន្យល់អំពីស្ថានភាពនេះ ហើយសុំយោបល់ពីពួកគេ។

11. You have been chosen to represent your school at a youth conference. Write the text of a speech you plan to give about the importance of continuing to study Khmer in high school.

    អ្នកត្រូវបានគេជ្រើសរើសជាតំណាងសាលា ទៅចូលរួមសន្និសីទយុវជន។
    ចូរសរសេរសុន្ទរកថាមួយដែលអ្នកមានគម្រោងនិយាយអំពីសារៈសំខាន់នៃការបន្តការសិក្សាភាសាខ្មែរនៅវិទ្យាល័យ។

*You may remove this page from the booklet by tearing along the perforations so that you will have the information in front of you for easy reference.*

You may make notes on this page.



PLEASE TURN OVER

This page is intentionally blank

Question Number:

**End of Section 3**